# លំហាត់ អនុវត្តលើមេរៀន ពហុធា

1. ដូចម្តេចដែលហៅថា ឯកធា? ចូរជ្រើសរើសឯកធា ក្នុងបណ្តាកន្សោមខាងក្រោម ៖

   $3x$ , $-2y$ , $4$ , $\frac{5}{z}$ , $2.3x^2y$ , $3y^{-1}z$ , $3\sqrt{xy}$ , $-\frac{2}{3}x$ , $7x-2$ , $\sqrt[5]{ab}$ រួចបញ្ជាក់ពីមេគុណ និងអថេររបស់វា។

2. ដូចម្តេចដែលហៅថាឯកធាដូចគ្នា ? ចូរជ្រើសរើសឯកធាដូចគ្នា ក្នុងបណ្តាឯកធាខាងក្រោម៖

   $5a$ , $12z$ , $3xy^2$ , $a$ , $2b$ , $-xy^2$ , $\frac{5}{6}z$ , $6$ , $ab$ ។

3. ដើម្បីរកដឺក្រេនៃឯកធាមួយ តើយើងត្រូវធ្វើដូចម្តេច ? ចូរប្រាប់ពី មេគុណ ដឺក្រេ និងអថេរ នៃឯកធាខាងក្រោម៖

   $a$ , $2$ , $2.35xa^2$ , $abc$ , $3ax^2$ , $\frac{7}{3}a^2bc$ , $1\frac{2}{3}x^3y^2z^5$ ។

4. ដើម្បីគណនាផលបូក ឬ ផលដកនៃឯកធាដូចគ្នា តើគេត្រូវធ្វើដូចម្តេច ? ចូរគណនា $2x-12x+2.4x$ ។

5. ដើម្បីគណនាផលគុណ នៃឯកធា តើគេត្រូវធ្វើដូចម្តេច ? ចូរគណនា $5xy\times 12aby$ ។

6. ដើម្បីគណនាផលចែក នៃឯកធា តើគេត្រូវធ្វើដូចម្តេច ? ចូរគណនា $60xy\div 15aby$ ។

7. ដូចម្តេចដែលហៅថា ពហុធា? ដូចម្តេចដែលហៅថា ទ្វេធា? ដូចម្តេចដែលហៅថា ត្រីធា? ដឺក្រេនៃពហុធា គឺជាអ្វី?

8. ដើម្បីធ្វើប្រមាណវិធីបូក ឬប្រមាណវិធីដកលើពហុធា តើគេត្រូវធ្វើដូចម្តេច? ដើម្បីគុណពហុធានឹងពហុធា តើគេត្រូវធ្វើដូចម្តេច?

9. ចូរបង្ហាញពីរូបមន្តពន្លាតកន្សោមដូចខាងក្រោម ៖

   ក. $(a+b)^2=?$ ខ. $(a-b)^2=?$ គ. $(a-b)(a+b)=?$ ឃ. $(a+b+c)^2=?$

   ង. $(a+b)^3=?$ ច. $(a-b)^3=?$ ឆ. $(a-b)(a^2+ab+b^2)=?$ ជ. $(a+b)(a^2-ab+b^2)=?$

10. ពន្លាត និងសម្រួលកន្សោមដូចខាងក្រោមឱ្យបានត្រឹមត្រូវ ៖

    ក. $5x+7x+x$ ខ. $x^2-10x^2+11x^2$ គ. $8x^2y^2z+13x^2y^2z-x^2y^2z$

    ឃ. $12x-17y-4(3x-5y)$ ង. $3x^2+4x-5y+3x(-x+2)$ ច. $(x^2+6x+8)-(x^2+2x-8)$

    ឆ. $(2x+1)^2-(2x+3)(2x-5)$ ជ. $(x-y)(4x+y)-(2x-y)(2x+y)$ ឈ. $(x+3y)^2-(x+y)(x+5y)$

    ញ. $x(x+2)-(x-1)(x+3)$ ដ. $(x-6y)(x^2+6xy+36y^2)$ ឋ. $(x-2y)(x^2+2xy+4y^2)$

    ឌ. $(x+y)(x^2-xy+y^2)$ ឍ. $(x-4y)(x^2+4xy+16y^2)$ ណ. $(5x-2y)(5x+2y)-(5x+y)^2$

    ត. $(x+3y)(x^2-3xy+9y^2)$ ថ. $(5x+y)(6x-y)$ ទ. $(x+7)^2-(x+8)(x+6)$

    ធ. $(4x-3)(3x+2)$ ន. $(x-3y)(x-5y)-(x-4y)^2$ ប. $(7x-5y)(3x+4y)+2y\times 10y$

    ផ. $(x-6)^2-(x+5)(x-8)$ ព. $(3x+4y)(3x-4y)$ ភ. $(x-6)(4x+3)-(2x-5)^2$

    ម. $(x+7y)(x-7y)$ យ. $(x+4)^2-(x-2)(x-8)$ រ. $(2a-3b)(4a+5b)$

    ល. $(3x-1)(x^2+7x-5)$ វ. $(x+1)(x-1)(x^2+1)$ ស. $(x+1)(x+9)-(x+3)^2$

    ហ. $(x+2)(x+8)-(x+4)^2$ ឡ. $(x^2+x-1)(x^2-x-1)-(x^2+1)^2$ អ. $(2a+b-c)^2-4a(a+b-c)$

11. កំណត់តម្លៃនៃ $a$ ដើម្បីឱ្យវាផ្ទៀងផ្ទាត់សមភាពខាងក្រោម៖

    ក. $(x+a)(x-8)=x^2-12x+32$ ខ. $(2y-6)(y+a)=2y^2+8y-42$

    គ. $4x^2-3ay^4=(2x+9y^2)(2x-9y^2)$ ឃ. $16x^2+5ay^4=(4x+5y^2)(4x-5y^2)$ ។



LIVEWORKSHEETS